State of California

Health and Human Services

DHCS

CalMediConnect
Your choice for complete care

▶Z-◀

JOHN SAMPLE
1234 SAMPLE STREET
ADDRESS 2
ANYTOWN CA 90000

XX/XX/XXXX

ព័ត៌មានសំខាន់

លោកអ្នកកំពុងទទួលសំបុត្រនេះដោយសារតែលោកអ្នកមានទាំង Medicare និង Medi-Cal។ វិធីដែលលោកអ្នកទទួលការថែទាំសុខភាពរបស់លោកអ្នកកំពុងផ្លាស់ប្តូរ។ លោកអ្នកឥឡូវនេះនឹងមានជម្រើសថែមទៀតដើម្បីបំពេញតម្រូវការថែទាំសុខភាពទាំងឡាយរបស់លោកអ្នក។

នេះគឺសំបុត្រទីពីរប្រាប់លោកអ្នកអំពីជម្រើសថ្មីទាំងឡាយរបស់លោកអ្នក។ លោកអ្នកអាចជ្រើសរើសគម្រោង Cal MediConnect មួយឬជ្រើសរើសនៅតែជាមួយ Medicare ធម្មតា។ បើលោកអ្នកជ្រើសរើសនៅតែជាមួយ Medicare ធម្មតា លោកអ្នកត្រូវតែជ្រើសរើសគម្រោងសុខភាព Medi-Cal មួយសំរាប់អត្ថប្រយោជន៍ Medi-Cal ទាំងឡាយរបស់លោកអ្នក។ បើលោកអ្នកមិនធ្វើការជ្រើសរើស យើងនឹងជ្រើសរើសគម្រោងមួយក្នុងចំណោមគម្រោង Cal MediConnect ទាំងឡាយសំរាប់លោកអ្នក។

ផ្អែកទៅលើសេវាកម្ម និងតម្រូវការថែទាំសុខភាពទាំងឡាយកន្លងទៅហើយ លោកអ្នកត្រូវបានចាត់អោយទៅគម្រោង Cal MediConnect ដែលមានឈ្មោះខាងក្រោម។ លើកលែងតែលោកអ្នកជ្រើសរើសនៅតែជាមួយ Medicare ធម្មតា លោកអ្នកមិនត្រូវការធ្វើអ្វីទេ ហើយការបង់ធានារ៉ាប់រងរបស់លោកអ្នកនៅក្នុងគម្រោងនេះនឹងមានប្រសិទ្ធិភាពនៅថ្ងៃ

MM/DD/YYYY: [Health Plan Name]

តើការផ្លាស់ប្តូរនេះនឹងប៉ះពាល់ខ្ញុំយ៉ាងដូចម្តេច?

ចុះឈ្មោះក្នុងគម្រោង Cal MediConnect មួយនឹង៖

- រក្សាទុកអត្ថប្រយោជន៍ Medicare ឬ Medi-Cal ទាំងឡាយរបស់លោកអ្នកដោយគ្មានគិតថ្លៃបន្ថែម។
- រក្សាទុកសេវាកម្ម ឬអត្ថប្រយោជន៍ទាំងអស់ដែលលោកអ្នកទទួលបានឥឡូវនេះ។
- ប្រាកដថាគ្រូពេទ្យ អ្នកជំនាញមុខ និងអ្នកផ្តល់ទាំងឡាយផ្សេងៗទៀតទាំងអស់នឹងធ្វើការជាមួយគ្នាដើម្បីអោយលោកអ្នកទទួលការថែទាំដែលលោកអ្នកត្រូវការ។
- ផ្តល់ការដឹកជញ្ជូននិងអត្ថប្រយោជន៍ផ្នែកបន្ថែមទៀត។

តើគម្រោង Cal MediConnect មួយជួយខ្ញុំយ៉ាងដូចម្តេច?

ការផ្លាស់ប្តូរកំពុងកើតឡើងដើម្បីអត្ថប្រយោជន៍ Medicare និង Medi-Cal ទាំងឡាយរបស់លោកអ្នកធ្វើការជាមួយគ្នាគ្រាន់បើជាងនិងដំណើរការប្រសើរជាងមុនសំរាប់លោកអ្នក។

ជម្រើសរបស់លោកអ្នករួមមាន៖

1. **ចុះឈ្មោះនៅក្នុងគម្រោង Cal MediConnect មួយ។** គម្រោង Cal MediConnect ទាំងឡាយបង់ធានារ៉ាប់រងសេវាកម្ម ទាំង Medicare និង Medi-Cal។ បើលោកអ្នកចូលរួមគម្រោង Cal MediConnect មួយ លោកអ្នកនឹងទទួល In-Home Supportive Services (IHSS), Multipurpose Senior Services Program (MSSP), Community-Based Adult Services (CBAS) និងការថែទាំមន្ទីរថែរក្សាតាមរយៈគម្រោង Cal MediConnect។ ពួកវាបង់ធានារ៉ាប់រងផងដែរនូវការថែទាំភ្នែក និងការដឹកជញ្ជូន។ គម្រោង Cal MediConnect នឹងធ្វើការជាមួយគ្រូពេទ្យនិងអ្នកផ្តល់ទាំងឡាយរបស់លោកអ្នកដើម្បីប្រាកដថាលោកអ្នកទទួលការថែទាំដែលលោកអ្នកត្រូវការ។

2. **ចុះឈ្មោះនៅក្នុង Program of All-inclusive Care for the Elderly (PACE)។** បើលោកអ្នកមានអាយុ 55 ឬចាស់ជាង ហើយត្រូវការកំរិតថែទាំខ្លាំងជាងដើម្បីរស់នៅផ្ទះ លោកអ្នកប្រហែលអាចចូលរួម PACE។ PACE ផ្តល់អត្ថប្រយោជន៍ Medicare និង Medi-Cal ទាំងឡាយ ថែមទាំងសេវាកម្មបន្ថែមមួយចំនួន ដើម្បីជួយជនចាស់ជរាដែលមានស្ថានភាពពុំរឹងរ៉ៃអោយរស់នៅផ្ទះ។

3. **ចុះឈ្មោះនៅក្នុងគម្រោងសុខភាព Medi-Cal មួយ។** បើលោកអ្នកជ្រើសរើសដើម្បីនៅតែជាមួយ Medicare ធម្មតា លោកអ្នកនឹងមិនត្រូវបានចាត់ទៅគម្រោង Cal MediConnect មួយ ប៉ុន្តែលោកអ្នកត្រូវតែនៅតែជ្រើសរើសគម្រោងសុខភាពមួយដើម្បីទទួល Medi-Cal។ ការចូលរួមនៅក្នុងគម្រោង Medi-Cal មួយនឹងអនុញ្ញាតអោយលោកអ្នករក្សាទុកគ្រូពេទ្យ និងមន្ទីរពេទ្យ Medicare ទាំងឡាយរបស់លោកអ្នក ហើយលោកអ្នកនឹងមិនបាត់បង់សេវាកម្មណាមួយ។ លោកអ្នកនឹងទទួល In-Home Supportive Services (IHSS), Multipurpose Senior Services Program (MSSP), Community-Based Adult Services (CBAS) និងការថែទាំក្នុងមណ្ឌលថែទាំជនចាស់ជរានិងជនមានពិការភាពតាមរយៈគម្រោង។

តើខ្ញុំគួរធ្វើអ្វីឥឡូវនេះ?

ពិនិត្យមើលឡើងវិញនូវជម្រើសទាំងបីខាងលើ ហើយសម្រេចថាមួយណាប្រសើរបំផុតសំរាប់លោកអ្នក។ ប្រើសៀវភៅណែនាំគម្រោងសុខភាព និងសៀវភៅជម្រើស ដែលនឹងមកដល់តាមប្រៃសណីយ៍ពី Health Care Options ដើម្បីជួយលោកអ្នក។ សួរគ្រូពេទ្យ និងអ្នកផ្តល់ការថែទាំសុខភាពផ្សេងៗទៀតរបស់លោកអ្នក ដើម្បីដឹងថាតើគម្រោងណាខ្លះដែលពួកគេធ្វើការជាមួយ។

លោកអ្នកមិនត្រូវការធ្វើអ្វីទេដើម្បីចូលរួមគម្រោង Cal MediConnect ខាងក្រោម។

បើលោកអ្នក<u>មិនចង់</u>ចុះឈ្មោះនៅក្នុង [Health Plan Name,]
លោកអ្នកអាចទាក់ទង Health Care Options ដើម្បីជ្រើសរើសគម្រោង Cal MediConnect មួយផ្សេងទៀត ឬនៅតែក្នុង Medicare ធម្មតា។ ទាក់ទង Health Care Options អោយទាន់

MM/DD/YYYY.

ទូរស័ព្ទមក Health Care Options តាមលេខខាងក្រោម ឬដោយបំពេញនិងផ្ញើត្រឡប់មកវិញនូវពាក្យសុំការជ្រើសរើស ដែលមានភ្ជាប់ជាមួយស្រោមសំបុត្រ។ ពាក្យសុំនេះគឺនៅក្នុងសៀវភៅជម្រើសរបស់លោកអ្នក ដែលនឹងមកតាមប្រៃសណីយ៍ពី Health Care Options។

សំរាប់ជំនួយឬព័ត៌មានថែមទៀត

បើលោកអ្នកចង់និយាយជាមួយទីប្រឹក្សាធានារ៉ាប់រងសុខភាពម្នាក់អំពីការផ្លាស់ប្តូរទាំងនេះ និងជម្រើសរបស់លោកអ្នក សូមទូរស័ព្ទទៅ **California Health Insurance Counseling & Advocacy Program (HICAP) តាមលេខ 1-800-434-0222។**

បើលោកអ្នកមានសំណួរអំពី Medicare សូមទូរស័ព្ទមក 1-800-MEDICARE (1-800-633-4227) 24 ម៉ោងមួយថ្ងៃ 7 ថ្ងៃមួយអាទិត្យ។ អ្នកប្រើ TTY គួរតែទូរស័ព្ទមក 1-877-486-2048។

បើលោកអ្នកចង់ជ្រើសរើសគម្រោង Cal MediConnect ផ្សេងមួយទៀត សូមស្ថិតនៅក្នុង Medicare ធម្មតា ឬទទួលសំបុត្រនេះជាភាសាផ្សេងទៀត ឬទ្រង់ទ្រាយផ្សេង ដូចជា អក្សរពុម្ពធំ សម្លេង ឬអក្សរសំរាប់មនុស្សពិការភ្នែក សូមទូរស័ព្ទមក Health Care Options ថ្ងៃចន្ទ - ថ្ងៃសុក្រ ម៉ោង 8 ព្រឹក - 5 ល្ងាច តាមលេខ 1-844-580-7272 ឬTTY: 1-800-430-7077

បើលោកអ្នកត្រូវការជំនួយថែមទៀត ទូរស័ព្ទមក **Cal MediConnect Ombudsman** តាមលេខ 1-855-501-3077។ លេខនេះនឹងដំណើរការចាប់ពីថ្ងៃ 4/1/2014។

សំណួរដែលត្រូវបានសួរញឹកញាប់ និងចម្លើយ

1. តើអ្វីជាភាពខុសគ្នារវាង Medicare និង Medi-Cal?

Medicare និង Medi-Cal គឺជាកម្មវិធីផ្សេងពីគ្នាពីរដែលបង់ធានារ៉ាប់រងសេវាកម្មខុសៗពីគ្នាសំរាប់បុគ្គលដែលមានសិទ្ធិចូលរួមទាំងឡាយ។ ដោយចូលរួមគម្រោង Cal MediConnect មួយ អត្ថប្រយោជន៍ Medicare និង Medi-Cal ទាំងឡាយរបស់លោកអ្នកប្រសើរជាងជាមួយគ្នា និងដំណើរការប្រសើរជាងមុនសំរាប់លោកអ្នក។

- **Medicare** បង់ធានារ៉ាប់រងសេវាកម្មវេជ្ជសាស្ត្រទាំងឡាយដូចជា គ្រូពេទ្យ អ្នកជំនាញមុខ មន្ទីរពេទ្យ និងថ្នាំវេជ្ជបញ្ជាទាំងឡាយ។ Medicare បង់ផងដែរនូវឧបករណ៍វេជ្ជសាស្ត្រមួយចំនួននិងសុខភាពតាមផ្ទះ។

- **Medi-Cal** បង់ធានារ៉ាប់រងថ្លៃទាំងឡាយនេះដែល Medicare មិនបង់ថ្លៃ រួមមាន៖

  a. ចំនួនថ្លៃដែលត្រូវបង់ខ្លួនឯង

  b. IHSS, CBAS, MSSP និងការថែទាំមនទីរថែទាំជនចាស់ជរានិងជនមានពិការភាព

  c. ការដឹកទៅការណាត់ជួបវេជ្ជសាស្ត្រទាំងឡាយ

  d. ឧបករណ៍និងគ្រឿងផ្គត់ផ្គង់វេជ្ជសាស្ត្រ ដូចជាបន្ទះរុំរបួស និងកន្ទបទាំងឡាយ។

2. តើអ្វីទៅជាអត្ថប្រយោជន៍ទាំងឡាយនៃការចុះឈ្មោះនៅក្នុង គម្រោង Cal MediConnect?

- លោកអ្នកនឹងទទួលអត្ថប្រយោជន៍ Medicare និង Medi-Cal ទាំងអស់របស់លោកអ្នកនៅក្នុងគម្រោងសុខភាពមួយ រួមទាំងគ្រូពេទ្យ មន្ទីរពេទ្យ និងថ្នាំវេជ្ជបញ្ជាទាំងឡាយ។

- លោកអ្នកនឹងទទួលកាតសមាជិកភាពមួយ និងលេខទូរស័ព្ទមួយដើម្បីទូរស័ព្ទទៅនៅពេលលោកអ្នកត្រូវការជំនួយ។

- លោកអ្នកនឹងទទួលការថែទាំភ្នែកនិងការដឹកជញ្ជូនទៅកាន់ការណាត់ជួបពិនិត្យសុខភាពទាំងឡាយ។

- លោកអ្នកអាចទូរស័ព្ទមកលេខទូរស័ព្ទដំបូន្មានគិលានុបដ្ឋាយិកា 24 ម៉ោង សំរាប់ជំនួយ។

- លោកអ្នកអាចទទួលបានអ្នកសម្របសម្រួលថែទាំម្នាក់។ មនុស្សម្នាក់នេះនឹងឆ្លើយសំណួរទាំងឡាយរបស់លោកអ្នក ជួយលោកអ្នកស្វែងរកសេវាកម្មសហគមន៍ ជួយលោកអ្នកនៅក្នុងការធ្វើការណាត់ជួបពិនិត្យសុខភាពរបស់លោកអ្នក និងជួយលោកអ្នកនិយាយជាមួយគ្រូពេទ្យទាំងឡាយរបស់លោកអ្នក។

- គម្រោង Cal MediConnect របស់លោកអ្នកនឹងសួរលោកអ្នកអំពីតម្រូវការថែទាំសុខភាពរបស់លោកអ្នក ហើយនិងធ្វើការជាមួយលោកអ្នកដើម្បីបង្កើតគម្រោងការថែទាំសុខភាពផ្ទាល់ខ្លួនមួយផ្អែកទៅលើគោលដៅទាំងឡាយរបស់លោកអ្នក។

3. តើខ្ញុំអាចប្រាកដថាការថែទាំរបស់ខ្ញុំនៅបន្ត បន្ទាប់ពីខ្ញុំចូលរួមគម្រោង Cal MediConnect?

គម្រោង Cal MediConnect ថ្មីរបស់លោកអ្នកគឺត្រូវបានតម្រូវអោយប្រាកដថាលោកអ្នកទទួលការថែទាំមានគុណភាពដែលលោកអ្នកត្រូវការ។ គម្រោង Cal MediConnect របស់លោកអ្នកនឹងទាក់ទងលោកអ្នកក្រោយពីលោកអ្នកចុះឈ្មោះដើម្បីរៀនអំពីតម្រូវការថែទាំសុខភាពរបស់លោកអ្នក។ ពួកគេនឹងធ្វើការជាមួយលោកអ្នកដើម្បីប្រាកដថាលោកអ្នកទទួលការថែទាំទាំងអស់ដែលលោកអ្នកត្រូវការ។

បើលោកអ្នកមានការព្យាបាលដែលបានកំណត់ពេល ហើយកំពុងផ្លាស់ប្តូរគម្រោងសុខភាពទាំងឡាយ សូមទូរស័ព្ទទៅគម្រោង Cal MediConnect ថ្មីរបស់លោកអ្នកភ្លាមៗ។ ប្រាប់គម្រោងសុខភាពអំពីការព្យាបាលនាពេលខាងមុខរបស់លោកអ្នកដើម្បីអោយពួកគេធ្វើការជាមួយលោកអ្នក។

- **បើលោកអ្នកជួបគ្រូពេទ្យដែលមិនចូលរួមក្នុងបណ្តាញរបស់គម្រោងសុខភាព** លោកអ្នកអាចបន្តជួបគ្រូពេទ្យនេះសំរាប់រហូតដល់ប្រាំមួយខែបើគ្រូពេទ្យយល់ព្រមជាមួយតម្លៃរបស់គម្រោងសុខភាពថ្មីរបស់លោកអ្នក ហើយមិនមានបញ្ហាគុណភាព។
- **បើលោកអ្នកនៅក្នុងមន្ទីរថែទាំជនចាស់ជរានិងជនមានពិការភាព Medi-Cal មួយ** គម្រោង Cal MediConnect នឹងធ្វើការជាមួយលោកអ្នក និងក្រុមថែទាំរបស់លោកអ្នក ដើម្បីអោយលោកអ្នកទទួលការថែទាំដែលលោកអ្នកត្រូវការ។ លោកអ្នកអាចនៅតែក្នុងមន្ទីរថែទាំជនចាស់ជរានិងជនមានពិការភាពរបស់លោកអ្នក។

4. តើខ្ញុំអាចធ្វើអ្វីបើខ្ញុំចូលរួមគម្រោង Cal MediConnect ឬ PACE មួយ ហើយខ្ញុំមិនចូលចិត្តវា?

នៅក្នុងខែណាក៏ដោយ លោកអ្នកអាចដកឈ្មោះពី Cal MediConnect ឬ PACE ហើយត្រឡប់ទៅគម្រោង Medicare ធម្មតា ឬគម្រោង Medicare Advantage មួយ។ ដើម្បីធ្វើការនេះ ទូរស័ព្ទមក Health Care Options តាមលេខ 1-844-580-7272 (TTY: 1-800-430-7077) ឬប្រាប់គម្រោងសុខភាពរបស់លោកអ្នកថាលោកអ្នកចង់ចាកចេញពីគម្រោង។ គម្រោងសុខភាពអាចជួយលោកអ្នកធ្វើការជ្រើសរើសនេះ។

- ចូរចាំថាលោកអ្នកនឹងនៅតែត្រូវបានចុះឈ្មោះនៅក្នុងគម្រោងសុខភាពសំរាប់អត្ថប្រយោជន៍ Medi-Cal ទាំងឡាយរបស់លោកអ្នក។ ការដកឈ្មោះរបស់លោកអ្នកគ្រាន់តែប៉ះពាល់នូវរបៀបដែលលោកអ្នកទទួលអត្ថប្រយោជន៍ Medicare ទាំងឡាយរបស់លោកអ្នកតែប៉ុណ្ណោះ។

5. តើអ្វីទៅគឺជា Long Term Services and Supports? តើពួកវានឹងដំណើរការយ៉ាងដូចម្តេចនៅក្នុងគម្រោងសុខភាពមួយ?

Long Term Services and Supports (LTSS) គឺជាអត្ថប្រយោជន៍ Medi-Cal ទាំងឡាយដែលជួយលោកអ្នកជាមួយតម្រូវការថែទាំផ្ទាល់ខ្លួនដែលកំពុងបន្ត។ នៅក្នុងគម្រោងសុខភាពមួយ សេវាកម្មនិងការគាំទ្រទាំងនេះនឹងដំណើរការដូចដែលពួកវាដំណើរការសព្វថ្ងៃនេះ។

គម្រោងសុខភាពរបស់លោកអ្នកនឹងធ្វើការជាមួយគ្រូពេទ្យ និងអ្នកផ្តល់ LTSS របស់លោកអ្នក។ បើលោកអ្នកមិនបានទទួលសេវាកម្មទាំងនេះឥឡូវនេះ គម្រោងសុខភាពរបស់លោកអ្នកអាចជួយលោកអ្នកទទួលបានពួកវានៅពេល អនាគត បើពួកវាចាំបាច់ខាងវេជ្ជសាស្ត្រ។

- In-Home Supportive Services (IHSS): សេវាកម្មការថែទាំផ្ទាល់ខ្លួនទាំងឡាយសំរាប់ជនដែលត្រូវការជំនួយដើម្បីរស់នៅអោយមានសុវត្ថិភាពនៅក្នុងផ្ទះរបស់ពួកគេ។
  - ▶ បើលោកអ្នកទទួល IHSS សេវាកម្មទាំងឡាយរបស់លោកអ្នកនឹងមិនផ្លាស់ប្តូរ។ លោកអ្នកអាចរក្សាទុកអ្នកផ្តល់ IHSS ទាំងឡាយរបស់លោកអ្នក ហើយលោកអ្នកអាចនៅតែជួល បណ្តេញពីការងារ និងគ្រប់គ្រងអ្នកផ្តល់ទាំងឡាយរបស់លោកអ្នក។ បុគ្គលិកសង្គមកិច្ចស្រុករបស់ IHSS នឹងនៅតែវាយតម្លៃតម្រូវការរបស់លោកអ្នកនិងអនុម័តម៉ោង IHSS របស់លោកអ្នក។ សិទ្ធិទាំងឡាយរបស់លោកអ្នកដើម្បីប្តឹងតវ៉ានឹងនៅតែដូចគ្នា។ បើលោកអ្នកចង់បាន គម្រោងសុខភាពរបស់លោកអ្នកអាចធ្វើការជាមួយលោកអ្នក និងអ្នកផ្តល់ IHSS ទាំងឡាយរបស់លោកអ្នកដើម្បីប្រាកដថាលោកអ្នកទទួលការថែទាំដែលលោកអ្នកត្រូវការ។

- Community-Based Adult Services (CBAS): ទាំងនេះគឺជាសេវាកម្មថែទាំសុខភាពពេលថ្ងៃនៅមណ្ឌលទាំងឡាយដែលផ្តល់ការថែទាំ វិធីព្យាបាល សកម្មភាព និងអាហារសំរាប់ជនទាំងឡាយណាដែលមានស្ថានភាពសុខភាពរ៉ាំរ៉ៃមួយចំនួន។
  - ▶ ខណៈដែលមានគម្រោងសុខភាពរបស់លោកអ្នកនឹងធ្វើការជាមួយលោកអ្នកនិងគ្រូពេទ្យរបស់លោកអ្នកបើលោកអ្នកត្រូវការសេវាកម្មនេះ។ បើលោកអ្នកទទួល CBAS សព្វថ្ងៃនេះ សេវាកម្មទាំងឡាយរបស់លោកអ្នកនឹងមិនផ្លាស់ប្តូរ។
- Multipurpose Senior Services Program (MSSP): ទាំងនេះគឺជាសេវាកម្មសង្គមនិងការសម្របសម្រួលការថែទាំសុខភាពសំរាប់ជនទាំងឡាយដែលមានអាយុ 65 ឬចាស់ជាង។
  - ▶ បើលោកអ្នកទទួលសេវាកម្ម MSSP ទាំងឡាយ លោកអ្នកនឹងនៅតែទទួលវាតាមរយៈអ្នកផ្តល់ MSSP បច្ចុប្បន្ន របស់លោកអ្នក។ គម្រោងសុខភាពរបស់លោកអ្នកនឹងធ្វើការជាមួយពួកគេដើម្បីសម្របសម្រួលការថែទាំរបស់លោកអ្នកអោយប្រសើរជាង។
- **ការថែទាំមន្ទីរថែទាំជនចាស់ជរានិងជនមានពិការភាព៖** គម្រោងសុខភាពរបស់លោកអ្នកនឹងធ្វើការជាមួយគ្រូពេទ្យនិងមន្ទីរថែរក្សារបស់លោកអ្នក ដើម្បីផ្តល់អោយលោកអ្នកនូវសេវាកម្មទាំងឡាយដូចគ្នាដែលលោកអ្នកបានទទួលឥឡូវនេះ ហើយសម្របសម្រួលការថែទាំរបស់លោកអ្នកអោយបានប្រសើរជាង។

6. ខ្ញុំមិនប្រើអត្ថប្រយោជន៍ Medi-Cal Long Term Services and Supports ណាមួយទេ។ ហេតុអ្វីក៏ខ្ញុំត្រូវតែចូលរួមក្នុងគម្រោងសុខភាពមួយ?

ហេតុផលសំរាប់ជម្រើសនេះគឺដើម្បីសម្របសម្រួលសេវាកម្ម Medi-Cal ទាំងឡាយរបស់លោកអ្នកអោយបានប្រសើរជាង។ បើលោកអ្នកត្រូវការ Long Term Services and Supports គម្រោងសុខភាពនឹងជួយលោកអ្នក។ នៅក្នុងគម្រោងសុខភាពមួយផងដែរ លោកអ្នកអាចទទួលការដឹកជញ្ជូនទៅការណាត់ជួបពិនិត្យសុខភាព និងហៅលេខទូរស័ព្ទដំបូន្មានគិលានុបដ្ឋាយិកា 24 ម៉ោងសំរាប់ជំនួយ។ គម្រោងសុខភាព Medi-Cal ទាំងឡាយនឹងបង់ថ្លៃ Medicare បន្ថែមដែលរដ្ឋបង់សព្វថ្ងៃនេះ ដូចជាចំនួនថ្លៃដែលត្រូវបង់ខ្លួនឯងរបស់លោកអ្នក។